ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..៤៤..សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការដេញថ្លៃលក់ឈើ និងកូនឈើ ដែលគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើចាប់បាន

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងសេចក្តីជូនដំណឹងលេខ ៤៦៥ សជណ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

## សម្រេច

**ប្រការ ១៖** ត្រូវបានបង្កើតគណៈកម្មការដេញថ្លៃលក់ឈើ និងកូនឈើ ដែលគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើចាប់បាន ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | អូន ព័ន្ធមុនីរ័ត្ន | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តម | សាយ សំអាល់ | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៣-ឯកឧត្តម | វេង សាខុន | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |



www.pheakdeylaw.com

| | | |
|---|---|---|
| ៤-ឯកឧត្តម អង្គ វង្សវឌ្ឍនា | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ៥-ឯកឧត្តម ហង់ ជួន ណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៦-ឯកឧត្តម ព្រុំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៧-ឯកឧត្តម ជូ វិជិត | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨-ឯកឧត្តម ឆេង គឹមស៊ុន | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុក ប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ៩-ឯកឧត្តមឧត្តមសេនីយ៍ឯក ហ៊ូ សាគុណ | តំណាងឯកឧត្តមនាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១០-ឯកឧត្តម ស្រ៊ុន ដារិទ្ធ | ទីប្រឹក្សាក្រសួងបរិស្ថាន | សមាជិក |
| ១១-ឯកឧត្តមឧត្តមសេនីយ៍ត្រី អេង ហ៊ី | តំណាងឯកឧត្តមនាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរងកង យោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជាប្រធានគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ | សមាជិក |
| ១២-ឯកឧត្តម សរ ចំរុង | អភិបាល នៃគណៈអភិបាលខេត្ត ក្រចេះ | សមាជិក |
| ១៣-ឯកឧត្តម ប្រាជ្ញ ចន្ទ | អភិបាល នៃគណៈអភិបាលខេត្ត ត្បូងឃ្មុំ | សមាជិក |
| ១៤-ឯកឧត្តម ម៉ុម សារឿន | អភិបាល នៃគណៈអភិបាលខេត្ត ស្ទឹងត្រែង | សមាជិក |
| ១៥-ឯកឧត្តម ថង សាវុន | អភិបាល នៃគណៈអភិបាលខេត្ត រតនគិរី | សមាជិក |
| ១៦-ឯកឧត្តម ស្វាយ សំអ៊ាង | អភិបាល នៃគណៈអភិបាលខេត្ត មណ្ឌលគិរី | សមាជិក។ |

**ប្រការ ២ ៖** គណៈកម្មការនេះមានភារៈកិច្ចរៀបចំឯកសារពាក់ព័ន្ធ កំណត់លក្ខណ្ឌ នីតិវិធី កាលបរិច្ឆេទ និងទីកន្លែង នៃការដេញថ្លៃលក់ឈើ និងកូនឈើ ជាសាធារណៈឱ្យបានឆាប់ ដើម្បីយកថវិកាដែលបានមកពីការដេញថ្លៃនោះ ទុកសម្រាប់ប្រើប្រាស់ក្នុងវិស័យអប់រំ។



www.pheakdeylaw.com

**ប្រការ ៣ ៖** គណៈកម្មការ ត្រូវអញ្ជើញអង្គភាពប្រឆាំងអំពើពុករលួយចូលរួមសង្កេតការណ៍នៅគ្រប់ដំណាក់កាល នៃនីតិវិធី។

**ប្រការ ៤ ៖** គណៈកម្មការនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការតាមការចាំបាច់។

**ប្រការ ៥ ៖** ក្នុងករណីប្រធានគណៈកម្មការអវត្តមាន ប្រធានគណៈកម្មការត្រូវចេញលិខិតជាលាយល័ក្ខអក្សរ ដើម្បីចាត់អនុប្រធាន ០១ រូប ដឹកនាំកិច្ចការជំនួស។

**ប្រការ ៦ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦

ការិយាល័យទីស្តីការគណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៦
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com